ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែតុលា ឆ្នាំ២០១៩

*នៅក្នុងខែតុលា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖*

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :**

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០២លើក ចាប់ពីថ្ងៃទី២៦ ខែសីហា រហូតដល់ថ្ងៃទី២ ខែតុលា និងពីថ្ងៃទី២១ ដល់២៤ ខែតុលា ឆ្នាំ២០១៩*

*-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០២លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក*

*-អញ្ជើញចូលរួមទទួលព្រះរាជដំណើរយាងនិវត្តន៍ ពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់មាតុប្រទេសវិញរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត*

*-អញ្ជើញចូលរួមជូន និងទទួលព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គយាងទៅបំពេញព្រះរាជកិច្ច និងយាងនិវត្តន៍ពីព្រះរាជាណាចក្រជប៉ុនមកកាន់មាតុប្រទេសវិញ*

*-អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅបរិវេណព្រះឧបោសថរតនារាម ព្រះវិហារព្រះកែវមរកត ក្នុងបរិវេណព្រះបរមរាជវាំង*

*-ទទួលសារតាំងពីឯកឧត្តម* Christian Berger *ឯកអគ្គរដ្ឋទូតតែងតាំងថ្មីនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចូលរួមប្រជុំក្រុមសមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញប្រារព្ធពិធីសូត្រមន្តបុណ្យកឋិនទានសាមគ្គី នៅគេហដ្ឋានផ្ទះលេខ២៨៣ ផ្លូវលេខ៦៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញដង្ហែអង្គកឋិនទានសាមគ្គីវេរប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សាអស់ត្រីមាសក្នុងពុទ្ធសីមា ដើម្បីប្រមូលបច្ច័យសាងសង់សមិទ្ធផលនានា ទុកជាគរុភណ្ឌក្នុងវត្តពង្សរង្សី (ហៅវត្តជ្រៃម្រាក់)ដែលស្ថិតនៅភូមិជ្រៃម្រាក់ ឃុំគោកគង់កើត ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៣៩ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ចំនួន ០៣លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក និងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក

-អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅបរិវេណព្រះឧបោសថរតនារាម ព្រះវិហារព្រះកែវមរកត ក្នុងបរិវេណព្រះបរមរាជវាំង

-អញ្ជើញជាអធិបតីក្នុងពិធីថ្ងៃសុន្ទរកថាបើកវេទិកាស្តីពី ការពង្រឹងសមត្ថភាពសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្តច្បាប់ពាក់ព័ន្ធអាពាហ៍ពិពាហ៍ និងគ្រួសារសន្តតិកម្ម និងការដោះស្រាយវិវាទក្រៅប្រព័ន្ធ នៅខេត្តពោធិ៍សាត់

-អញ្ជើញទទួលជួបសវនាការជាមួយនឹងឯកឧត្តម LIU Hongcai អនុប្រធានសមាគមយោគយល់ជាអន្តរជាតិ និងជាអនុប្រធានគណៈកម្មាធិការកិច្ចការបរទេស នៃសភាប្រឹក្សានយោបាយប្រជាជនចិន និងជាអតីតអនុរដ្ឋមន្ត្រីនៃក្រសួងទំនាក់ទំនងអន្តរជាតិនៃគណបក្សកុម្មុយនីស្តចិន និងបានចូលរួមពិសាអាហារសាមគ្គីជាមួយឯកឧត្តម ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា

-អនុញ្ញាតឱ្យឯកឧត្តម ZHANG BAOSHUN អនុប្រធានគណៈកម្មាធិការធនធានប្រជាជន និងបរិស្ថាននៃសភាប្រឹក្សានយោបាយប្រជាជនចិន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ព្រមទាំងអញ្ជើញចូលរួមពិសាអាហារសាមគ្គីជាមួយឯកឧត្តម ក្នុង

៨-ពិនិត្យ និងសម្រេចរបាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៤

៩-កំណត់របៀបវារៈ និងកាលបរិច្ឆេទប្រជុំព្រឹទ្ធសភាជាវិសាមញ្ញនីតិកាលទី៤។

**៣-សម័យប្រជុំពេញអង្គព្រឹទ្ធសភា**

ព្រឹទ្ធសភាបានបើកសម័យប្រជុំពេញអង្គចំនួន០១លើកដើម្បីៈ

១-ស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភា នីតិកាលទី៤។

**៤-កិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ**

ព្រឹទ្ធសភាបានបើកសម័យប្រជុំវិសាមញ្ញចំនួន០១លើកដើម្បីៈ

១-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងអង្គការហាមឃាត់អាវុធគីមីស្តីពី បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់អង្គការហាមឃាត់អាវុធគីមី

២-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី របបសន្តិសុខសង្គម

៣-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី សំណង់

៤-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

៥-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី កិច្ចការពារអ្នកប្រើប្រាស់

៦-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

៧-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ព្រឹទ្ធសភា។

**៥-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែតុលានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**៥.១-មុខងារនីតិកម្ម**

-គណៈកម្មការជំនាញរបស់ព្រឹទ្ធសភា បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់ ។

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទទួលជួបភ្ញៀវជនជាតិជប៉ុន និងនិស្សិតកម្ពុជា មកសិក្សាឈ្វេងយល់អំពី រោងចក្រចនាសម្ព័ន្ធ និងចំការឈើហូបផ្លែ បន្ទប់បង្ការ កសិដ្ឋានចិញ្ចឹមមាន់ ស្រះទឹកចិញ្ចឹមត្រី និងទស្សនាព្រៃឈើរាប់លានដើម នៅក្នុងតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ **ម៉ុង ឫទ្ធី** សែនជ័យ ។

ថ្ងៃ ពុធ ១០កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ